

# ពូជស្រូវសំខាន់ៗសម្រាប់ផលិតកម្មស្រូវ និងនាំអង្ករចេញ

ដើម្បីសម្រេចនូវគោលនយោបាយស្តីពីការជំរុញផលិកម្មស្រូវ និងការនាំអង្ករចេញរបស់រាជរដ្ឋាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានដាក់ចេញឲ្យប្រើប្រាស់ពូជស្រូវដែលមានទិន្នផល និងគុណភាពអង្ករខ្ពស់ចំនួន១០ពូជដែលក្នុងនោះមានៈ

១. ពូជស្រូវស្រាលមិនប្រកាន់រដូវចំនួន៣ពូជគឺ**ពូជសែនពិដោរ ពូជអ៊ីអ៊ែរ៦៦ ពូជជលសារ**។

២.ពូជស្រូវកណ្តាលប្រកាន់រដូវចំនួន៤ពូជគឺ ពូជ**ផ្ការំដួល ពូជផ្ការំដេង ពូជផ្ការមៀត** និង**ពូជផ្កាច័ន្ទសែនស**។

៣. ពូជស្រូវធ្ងន់ប្រកាន់រដូវមានចំនួន៣ពូជគឺ **ពូជរាំងជ័យ ពូជខា៤** និង**ពូជខា៦**។

## ១. ពូជស្រូវស្រាលមិនប្រកាន់រដូវ

### ១.១.លក្ខណៈពិសេសរបស់ពូជស្រូវ

*ក. ពូជស្រូវសែនពិដោរ*



ពូជសែនពិដោរ ជាប្រភេទពូជស្រូវស្រាល និងជាពូជស្រូវក្រអូប ដែលបានបញ្ចេញ និងផ្សព្វផ្សាយឲ្យកសិករប្រើប្រាស់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅដើមឆ្នាំ២០០២ ហើយមកដល់បច្ចុប្បន្ននេះពូជស្រូវសែនពិដោរ កំពុងប្រើប្រាស់ក្នុងផលិតកម្មស្រូវរដូវប្រាំងនិងស្រូវស្រាលដើមរដូវដោយកសិករ នៅទូទាំងប្រទេស ។ ពូជនេះមានទិន្នផលខ្ពស់មានក្លិនក្រអូប មានគុណភាពអង្ករល្អមានភាពភ្លឺថ្លាវែងរលូន និងបាយទន់ឆ្ងាញ់ពិសារ ជាពិសេសជាពូជមានប្រភេទអង្ករ មានតម្លៃខ្ពស់នៅក្នុងទីផ្សារជាតិ និងទីផ្សារអន្តរជាតិ។

ពូជសែនពិដោរ ជាប្រភេទពូជស្រូវមិនប្រកាន់រដូវ ដែលអាចដាំដុះបាននៅគ្រប់រដូវកាល ជាពិសេស ស្រូវដើមរដូវ នៅរដូវវស្សា ស្រូវប្រដេញទឹក និងស្រូវរដូវប្រាំង។ ពូជនេះមានអាយុកាលចាប់ពីថ្ងៃសាប រហូតដល់ពេលច្រូតកាត់ ពី ១១០ ថ្ងៃ - ១២០ ថ្ងៃមានកម្ពស់ដើមពី៩៥ស.ម - ១១០ ស.ម ចំនួនដើមបែកផ្តល់ផលពី ៥ - ២០ដើមក្នុង១គុម្ព ប្រវែងកួរមានពី ២០ ទៅ ៣០ ស.ម និងចំនួនគ្រាប់ក្នុង១កួរមានពី ១១០ - ១៧០គ្រាប់។ ពូជសែនពិដោរ ជាប្រភេទពូជមិនធន់នឹងមមាចត្នោត ហើយមានទិន្នផលពី ៣,៥តោន - ៥.៥តោនក្នុង១ហិកតាហើយបើក្នុងលក្ខខណ្ឌអំណោយផលល្អវាអាចផ្តល់ទិន្នផលរហូតដល់៨ទៅ10តោនក្នុង១ហិកតា។

*ខ. ពូជស្រូវអ៊ីអ៊ែរ៦៦*

ពូជស្រូវអ៊ីអ៊ែរ៦៦ ជាប្រភេទពូជស្រូវស្រាល ដែលបានបញ្ចេញ និងផ្សព្វផ្សាយឲ្យកសិករ ប្រើប្រាស់ដោយក្រសួង

កសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅដើមឆ្នាំ១៩៩០ ហើយមកដល់បច្ចុប្បន្ននេះ ពូជស្រូវអ៊ីអ៊ែរ៦៦ កំពុងប្រើប្រាស ក្នុងផលិតកម្មស្រូវរដូវប្រាំង និង ស្រូវស្រាលដើមរដូវ ដោយកសិករ នៅទូទាំងប្រទេស។ ពូជនេះមានទិន្នផលខ្ពស់ មានគុណភាពអង្ករល្អមានភាពភ្លឺថ្លាវែងរលូន និងជាពូជមានប្រភេទ អង្ករអាចលក់បាននៅក្នុងទីផ្សារជាតិ និងទីផ្សារអន្តរជាតិ។

ពូជស្រូវអ៊ីអ៊ែរ៦៦ ជាប្រភេទពូជស្រូវមិនប្រកាន់រដូវ ដែលអាចដាំដុះបាននៅគ្រប់រដូវកាល ជាពិសេសស្រូវដើមរដូវ នៅរដូវវស្សា ស្រូវប្រដេញទឹក និងស្រូវរដូវប្រាំង។ ពូជនេះមានអាយុកាលចាប់ពីថ្ងៃសាប រហូតដល់ពេលច្រូតកាត់ ពី ១០៥ ថ្ងៃ - ១១៥ ថ្ងៃ មានកម្ពស់ដើមពី ៨០ស.ម - ១១៨ស.ម ចំនួនដើមបែកផ្តល់ផលពី ១២ - ១៨ ដើមក្នុង ១ គុម្ព ប្រវែងកួរមានពី ២៥ ទៅ ២៦ ស.ម និងចំនួនគ្រាប់ក្នុង១កួរមានពី ១០០ - ១២០គ្រាប់។ ពូជស្រូវអ៊ីអ៊ែរ ៦៦ ជាប្រភេទពូជមិនធន់នឹងមមាចត្នោត ហើយមានទិន្នផលពី ៤.៥ តោន - ៦.៥ តោនក្នុង១ហិកតា ហើយបើក្នុងលក្ខខណ្ឌអំណោយផលល្អ និងការដាំដុះអនុវត្តតាមប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ វាអាចផ្តល់ទិន្នផលរហូតដល់៨ទៅ១០តោនក្នុង១ហិកតា។






*គ. ពូជស្រូវជលសារ*

ពូជស្រូវជលសារ ជាប្រភេទពូជស្រូវស្រាល ដែលបានបញ្ចេញ និង ផ្សព្វផ្សាយឲ្យកសិករប្រើប្រាស់ ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅដើមឆ្នាំ១៩៩៩ ហើយមកដល់បច្ចុប្បន្ននេះ ពូជស្រូវជលសារ បានកំពុងប្រើប្រាស់ក្នុងផលិតកម្មស្រូវរដូវប្រាំង និងស្រូវស្រាលដើមរដូវ ដោយកសិករនៅទូទាំងប្រទេស។ ពូជនេះមានទិន្នផលខ្ពស់ មានគុណភាពអង្ករល្អមានភាពភ្លឺថ្លាវែងរលូន និងជាពូជមានបាយទន់ឆ្ងាញ់។




ពូជស្រូវជលសារ ជាប្រភេទពូជស្រូវមិនប្រកាន់រដូវ ដែលអាចដាំដុះបាននៅគ្រប់រដូវកាលជាពិសេស ស្រូវដើមរដូវ នៅរដូវវស្សា ស្រូវប្រដេញទឹក និងស្រូវរដូវប្រាំង។ ពូជនេះមានអាយុកាលចាប់ពីថ្ងៃសាប រហូតដល់ពេលច្រូតកាត់ ពី ៩៥ ថ្ងៃ ទៅ១១៥ ថ្ងៃ មានកម្ពស់ដើមពី៧៥ស.ម ទៅ ៩៥ ស.ម ចំនួនដើមបែកផ្តល់ផលពី១០ ទៅ១៤ដើមក្នុង១គុម្ព ប្រវែងកួរមានពី២០ ទៅ ២៧ស.ម និងចំនួនគ្រាប់ក្នុង១កួរមានពី១០០ ទៅ ១៥០គ្រាប់។ ពូជស្រូវជលសារ ជាប្រភេទពូជមិនធន់នឹងមមាចត្នោត ហើយមានទិន្នផលពី ៤.០តោន ទៅ ៦.០តោនក្នុង១ហិកតា ហើយបើក្នុងលក្ខខណ្ឌអំណោយផលល្អ និងការដាំដុះអនុវត្តតាមប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ វាអាចផ្តល់ទិន្នផលរហូតដល់៧ទៅ៨តោន ក្នុង១ហិកតា។

**១.២.បច្ចេកទេសដាំដុះ**

### ក.សម្រាប់ស្រូវសន្ទូង

*សំណាប:* ដើម្បីឲ្យសំណាប និងដើមស្រូវមានសុខភាពល្អ ត្រូវប្រើពូជស្រូវសុទ្ធ និងមាន គុណភាពល្អ ដោយប្រើពូជពី២០ ទៅ ៤០គីឡូក្រាមសម្រាប់ស្ទូង១ហិកតា។ ថ្នាលសំណាបត្រូវនៅជិតប្រភពទឹកដោយរៀបចំដីថ្នាលសំណាបឲ្យបានស្មើល្អ

ដោយភ្ជួរ និងរាស់ឲ្យបានច្រើនដង និងកៀរដីថ្នាលរួចប្រើ ដីកំប៉ុស្តពី២ ទៅ ៣រទេះគោលើផ្ទៃដីសំណាប។ សាបគ្រាប់ស្រូវ ១គីឡូក្រាម លើផ្ទៃដីថ្នាល១០ម៉ែត្រការ៉េ ដើម្បីឲ្យសំណាបដុះលូតលាស់ល្អ ។ សំណាបមានអាយុកាលពី១៥ ទៅ ២០ថ្ងៃ ត្រូវដកយកទៅសន្ទូង ដោយដកភ្លាមស្ទូងភ្លាមនៅក្នុងថ្ងៃតែមួយ។

*សន្ទូង:*



សំណាបមានអាយុកាលពី១៥ ទៅ ២០ត្រូវដកយកទៅស្ទូងដោយ ដកភ្លាមស្ទូងភ្លាម នៅក្នុងថ្ងៃតែមួយ ។ ស្រែសន្ទូងត្រូវភ្ជួរឲ្យបាន ២ ទៅ៣ដងនិងរាស់កៀរដីឲ្យបាន រាបស្មើល្អ និងលើកភ្លឺស្រែឲបាន ខ្ពស់និងជាប់ល្អ និងប្រើដីកំប៉ុស្ត ឬ ដីលាមកគោរលួយពុកល្អចំនួន ៥ តោន ឬ ២០រទេះគោ និងអាច ប្រើដីដេ អា ប៉េ ចំនួន៥០គ.ក្រ ទៅ ១០០គ.ក្រ ទ្រាប់បាត តាមប្រភេទដី ។ ស្ទូង ១ ដើម ទៅ ៣ ដើមក្នុង១គុម្ពជាជួរ ឬមុំចង្រានដោយស្ទូងចំនួន ២០ គុម្ព ទៅ ២៥គុម្ពក្នុង១ម៉ែត្រការ៉េ។ បើដីមិនសូវមានជីជាតិអាចប្រើជីអ៊ុយរ៉េបំប៉នពី៥០ - ១០០ គ.ក្រក្នុង១ហិកតា នៅពេលស្រូវមួរដើម ឬពេលស្រូវកកើតកូរ។ នៅពេលស្ទូងរួចរយៈពេល៥-៧ថ្ងៃ ត្រូវស្ទូងជួសគុម្ពណាដែលបាត់ ចុះមើលស្រែជាប្រចាំនិងបោចស្មៅគ្រប់គ្រងថែទាំទឹកក្នុងស្រែ និងត្រួតពិនិត្យសត្វល្អិត ជំងឺសត្វមានប្រយោជនិ នៅក្នុងស្រែជាប្រចាំ។

## ១.សម្រាប់ស្រូវពង្រោះ

*ការរៀបចំដីស្រែពង្រោះ និងព្រោះគ្រាប់ស្រូវ:* ត្រូវភ្ជួរដីឲ្យបានច្រើនដងពី២ ទៅ ៣ ដង ហើយរាស់កៀរដីឲ្យរាបស្មើល្អ និងប្រើជីកំប៉ុស្ត ឬ ជីលាមកគោដែលរលួយពុកល្អចំនួន៣-៥ តោន ឬ១៥ ទៅ ២០រទេះគោតាមលទ្ធភាពរកបាន។



ព្រោះគ្រាប់ស្រូវពី៧០-១០០ គីឡូក្រាមក្នុង១ហិកតាដោយប្រើឧបករណ៍ ព្រោះគ្រាប់ជាជួរឬ ព្រោះដោយដៃឲមានចំនួនដើមស្រូវពី១០០-១៥០ដើមក្នុង១ម៉ែត្រការ៉េ ឬ ចំនួនដើមផ្តល់ផល ឬ កួរ ពី៥០០ ទៅ ៦០០ដើមក្នុង១ម៉ែត្រការ៉េ (IRRI.;2009) ។

*ការប្រើប្រាស់ជី និងការថែទាំ:*

បើដីស្រែមិនសូវមានជីជាតិអាចប្រើជីបន្ថែមដោយប្រើជីដេ អា ប៉េ ចំនួន ៥០-១០០ គីឡូក្រាម ជីប៉ូតាស២៥គីឡូក្រាមក្នុង១ហិកតានៅពេលក្រោយព្រោះ១៥ ទៅ ២០ថ្ងៃ និងប្រើជីបំប៉ន ជីអ៊ុយរ៉េចំនួនពី៥០ គីឡូក្រាម និងជីប៉ូតាសចំនួន២៥គីឡូក្រាមក្នុង១ហិកតានៅពេលស្រូវមួរដើម ឬកកើតកួរ។

ក្រោយពេលព្រោះរួចរយៈពេល១៥ ទៅ ២០ថ្ងៃ ត្រូវស្ទូងជួសដើមណាដែលបាត់ ហើយចុះមើលស្រែជាប្រចាំ និងបោចស្មៅគ្រប់គ្រងថែទាំទឹកក្នុងស្រែ និងត្រួតពិនិត្យសត្វល្អិត ជំងឺ និងសត្វមានប្រយោជន៍នៅក្នុងស្រែជាប្រចាំ។

## **១.៣. ការប្រមូលផលនិងទុកដាក់គ្រាប់ស្រូវ**

*ការប្រមូលផលនិងទុកដាក់គ្រាប់ស្រូវ:*



ត្រូវច្រូតកាត់នៅក្រោយពេលស្រូវចេញផ្កាស្រុះ រយៈពេល ៣០-៣៥ថ្ងៃ ឬ ពេលដែលគ្រាប់ស្រូវទុំប្រមាណ៨៥ភាគរយ ពេលគ្រាប់ស្រូវមានសភាពរឹង តែមិនស្រួយបាក់នៅពេលយកមកខាំ និងគ្រាប់ស្រូវមានអត្រាសំណើម២០- ២២ភាគរយ។ ត្រូវបោកបែនភ្លាមក្រោយពីច្រូតកាត់ និងហាលគ្រាប់ស្រូវ២-៣ថ្ងៃ ឲ្យសំណើមគ្រាប់មាន ១៤ភាគរយ ឬ គ្រាប់ស្រូវស្ងួតល្អមានសភាពរឹងតែមិនស្រួយបាក់ពេលខាំ។ដើម្បីឲ្យគ្រាប់ស្រូវស្ងួតល្អ ត្រូវទុកដាក់គ្រាប់ស្រូវក្នុងបាវក្រចៅ ឬ ជង្រុកដែលជាទីកន្លែងស្ងួត និងមានខ្យល់ចេញចូលបានល្អ និងការពារបាននូវការបំផ្លាញពីសត្វល្អិត(ខ្មូត) និងសត្វកណ្តុរ ។ ត្រូវកត់ត្រាថ្ងៃ ខែពេលប្រមូលផលនៅលើបាវ ស្រូវ ឬ ជង្រុកស្រូវ ។

## ២. ពូជស្រូវកណ្តាលប្រកាន់រដូវ

### ២.១.លក្ខណៈពិសេសរបស់ពូជស្រូវ

*ក. ពូជស្រូវក្រអូបផ្ការំដួល*

ពូជផ្ការំដួលជាពូជស្រូវក្រអូប ដែលបានបញ្ចេញ និង ផ្សព្វផ្សាយឲ្យកសិករប្រើប្រាស់ ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅឆ្នាំ១៩៩៩ ហើយមកដល់បច្ចុប្បន្ននេះ ពូជស្រូវផ្ការំដួល កំពុងពេញនិយមប្រើប្រាស់ក្នុងផលិតកម្មស្រូវវស្សា ដោយកសិករនៅទូទាំងប្រទេស។ ពូជនេះមានទិន្នផលខ្ពស់ មានក្លិនក្រអូប មានគុណភាពអង្ករល្អមានភាពភ្លឺថ្លាវែងរលូន និងបាយទន់ឆ្ងាញ់ពិសារ ជាពិសេសជាពូជមានប្រភេទអង្ករមានតម្លៃខ្ពស់នៅក្នុងទីផ្សារជាតិ និងទីផ្សារអន្តរជាតិ។






ពូជផ្ការំដួល ជាប្រភេទពូជស្រូវកណ្តាល ប្រកាន់រដូវមធ្យមចាប់ចេញផ្កានៅពាក់កណ្តាលខែតុលា និងច្រូតកាត់ នៅពាក់កណ្តាលខែវិច្ឆិកា អាស្រ័យតាមអាកាសធាតុ និងពេលវេលាដាំដុះ។ ពូជនេះ មានកម្ពស់ដើមពី ១១០ស.ម ទៅ១៧០ស.ម ចំនួនដើមបែកផ្តល់ផលពី ៥ ទៅ ១០ដើមក្នុង១គុម្ព។ បើក្នុងលក្ខខណ្ឌដីមានជីជាតិល្អ និងអនុវត្តដាំដុះតាមប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ ចំនួនដើមបែក ផ្តល់ផលអាចមានទៅដល់ ១៤ ទៅ ១៨ ដើមក្នុង១គុម្ព។ ប្រវែងកួរមានពី២០ ទៅ ៣០ស.ម និងចំនួនគ្រាប់ក្នុង ១កួរមានពី១១០ ទៅ ១៥០គ្រាប់។ ពូជផ្ការំដួល ជាប្រភេទពូជធន់នឹងការលិចទឹកជំនន់បានល្អតែវាមិនសូវធន់នឹងមមាចត្នោតទេ ហើយមានទិន្នផលពី ៣.៥តោន ទៅ ៥.៥តោនក្នុង១ហិកតា។

*ខ. ពូជស្រូវក្រអូបផ្ការំដេង*

ពូជផ្ការំដេងជាពូជស្រូវក្រអូប ដែលបានបញ្ចេញ និង ផ្សព្វផ្សាយឲ្យកសិករប្រើប្រាស់ ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅឆ្នាំ២០០៦ ហើយមកដល់បច្ចុប្បន្ននេះ ពូជស្រូវផ្ការំដេង កំពុងពេញនិយមប្រើប្រាស់ និងប្រជាកសិករធ្វើការដាំដុះនៅក្នុងផលិតកម្មស្រូវរដូវវស្សាទូទាំងប្រទេស ។ ពូជនេះមានទិន្នផលខ្ពស់មានក្លិនក្រអូបមានគុណភាពអង្ករល្អ មានភាពភ្លឺថ្លាវែងរលូន និងបាយទន់ឆ្ងាញ់ពិសារ ជាពិសេសជាពូជមានប្រភេទអង្ករមានតម្លៃខ្ពស់នៅក្នុងទីផ្សារជាតិ និងទីផ្សារអន្តរជាតិ។

ពូជផ្ការំដេង ជាប្រភេទពូជស្រូវកណ្តាលប្រកាន់រដូវមធ្យម ចាប់ចេញផ្កានៅពាក់កណ្តាលខែតុលា និងច្រូតកាត់នៅពាក់កណ្តាលខែវិច្ឆិកា អាស្រ័យតាមអាកាសធាតុ និងពេលវេលាដាំដុះ។ ពូជនេះមានកម្ពស់ដើមពី១០០ស.ម -១៧៥ ស.ម




វប្បកម្មដំណាំស្រូវ ចំនួនដើមបែក ផ្ដល់ផលអាចមានទៅដល់២០-២៥ដើមក្នុង១គុម្ព ។ ប្រវែងកួរមានពី២០ ទៅ ៣០ស.ម និងចំនួនគ្រាប់ក្នុង១កួរមានពី១១០ - ១៥០គ្រាប់។ ពូជផ្ការំដេង ជាប្រភេទពូជធន់ទៅនឹងទឹកលិច ឬ ទឹកជំនន់ ប៉ុន្តែវាមិនសូវធន់នឹងមមាចត្នោតទេ ហើយមានទិន្នផលពី ៣.៥តោន ទៅ ៥.៨តោនក្នុង១ហិកតា។

*គ. ពូជស្រូវក្រអូបផ្ការមៀត*

ពូជផ្ការមៀតជាពូជស្រូវក្រអូប ដែលបានបញ្ចេញ និង ផ្សព្វផ្សាយឲ្យកសិករប្រើប្រាស់ ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅឆ្នាំ២០០៦ ហើយមកដល់បច្ចុប្បន្ននេះ ពូជស្រូវផ្ការមៀត កំពុងពេញនិយមប្រើប្រាស់ក្នុងផលិតកម្មស្រូវវស្សាដោយកសិករនៅទូទាំងប្រទេស។ ពូជនេះមានទិន្នផលខ្ពស់ មានក្លិនក្រអូប មានគុណភាពអង្ករល្អ មានភាពភ្លឺថ្លាវែងរលូន និងបាយទន់ឆ្ងាញ់ពិសារ ជាពិសេសជាពូជមានប្រភេទអង្ករមានតម្លៃខ្ពស់នៅក្នុងទីផ្សារជាតិ និងទីផ្សារអន្តរជាតិ។

ពូជផ្ការមៀត ជាប្រភេទពូជស្រូវកណ្តាលប្រកាន់រដូវមធ្យម ចាប់ចេញផ្កាពីថ្ងៃ១៥ ទៅ ២៥ ខែតុលា និងច្រូតកាត់នៅពាក់កណ្តាលទៅចុងខែវិច្ឆិកា អាស្រ័យតាមអាកាសធាតុ និងពេលវេលាដាំដុះ។ ពូជនេះមានកម្ពស់ដើមពី ១០០ស.ម




ទៅ១៥០ស.ម ចំនួនដើមបែកផ្ដល់ផលពី៨ -១៨ដើមក្នុង១គុម្ពបើក្នុងលក្ខខណ្ឌដីមានជីជាតិល្អ និងអនុវត្តដាំដុះតាមប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ ចំនួនដើមបែក ផ្ដល់ផលអាចមានទៅដល់២០-២៥ដើមក្នុង១គុម្ព ។ ប្រវែងកួរមានពី ២០ ទៅ ៣០ស.ម និងចំនួនគ្រាប់ក្នុង១កួរមានពី១១០ ទៅ ១៥០គ្រាប់។ ពូជផ្ការំដេងជាប្រភេទពូជធន់ទៅនឹងទឹកលិច ឬ ទឹកជំនន់រយៈពេលមធ្យម ប៉ុន្តែវាមិនសូវធន់នឹងមមាចត្នោតទេ ហើយមានទិន្នផលពី ៣.៥ តោន ទៅ ៥.៨តោនក្នុង១ហិកតា។

*ឃ. ពូជស្រូវកណ្តាលផ្កាច័ន្ទសែនសរ*



ពូជផ្កាច័ន្ទសែនសរ ជាពូជស្រូវដែលបានបញ្ចេញ និង ផ្សព្វផ្សាយឲ្យកសិករប្រើប្រាស់ ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅចុងឆ្នាំ២០០៩ ហើយមកដល់បច្ចុប្បន្ននេះ ពូជស្រូវផ្ការំដេង បានចាប់ផ្តើមនិងកំពុងពេញនិយមប្រើប្រាស់ ក្នុងផលិតកម្មស្រូវវស្សារបស់កសិករនៅ



កម្ពុជា។ ពូជនេះមានទិន្នផលខ្ពស់ មានគុណភាពអង្ករល្អ មានភាពភ្លឺថ្លាវែងរលូន និងបាយទន់ឆ្ងាញ់ពិសារជាពិសេស ជាពូជមានប្រភេទអង្ករមានតម្លៃ នៅក្នុងទីផ្សារជាតិ និង ទីផ្សារអន្តរជាតិ។

ពូជផ្កាច័ន្ទសែនសរ ជាប្រភេទពូជស្រូវកណ្តាលប្រកាន់រដូវមធ្យម ចាប់ចេញផ្កានៅចុងខែតុលាទៅដល់ដើមខែវិច្ឆិកា និងច្រូតកាត់នៅដើមខែធ្នូ អាស្រ័យតាមអាកាសធាតុនិងពេលវេលាដាំដុះ។ ពូជនេះមានកម្ពស់ដើមពី ១៥០ ស.ម - ១៦០ស.ម ចំនួនដើមបែកផ្តល់ផលពី ៧ ទៅ ១០ ដើមក្នុង១គុម្ព។ បើក្នុងលក្ខខណ្ឌដីមានជីជាតិល្អ និងអនុវត្តដាំដុះតាមប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ ចំនួនដើមបែកផ្តល់ផលអាចមានទៅដល់១៥ ទៅ ២០ ដើមក្នុង១គុម្ព។ ប្រវែងកួរមានពី២០ ទៅ ៣០ ស.ម និងចំនួនគ្រាប់ក្នុង១កួរមានពី១៦៩ ទៅ ២៣៣គ្រាប់។ ពូជផ្កាច័ន្ទសែនសរ មានទិន្នផលពី ៣.៥តោន ទៅ ៥.០តោនក្នុង១ហិកតា។

**២.២. បច្ចេកទេសដាំដុះ**

## ក. សម្រាប់ស្រូវសន្ទូង

*សំណាប:* ដើម្បីឲ្យសំណាប និងដើមស្រូវមានសុខភាពល្អ ត្រូវប្រើពូជស្រូវសុទ្ធ និងមាន គុណភាពល្អ ដោយប្រើពូជពី២០ ទៅ ៤០គីឡូក្រាមសម្រាប់ស្ទូង១ហិកតា ។ បើស្ទូងតាមប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវវិញ ប្រើពូជតែពី១៥ ទៅ ២០គីឡូក្រាមសម្រាប់ស្ទូង១ហិកតា ។ ថ្នាលសំណាបត្រូវនៅជិតប្រភពទឹកត្រូវរៀបចំដីថ្នាលសំណាបឲ្យបានស្មើល្អ ដោយភ្ជួរនិងរាស់ឲ្យបានច្រើនដង និងកៀរដីថ្នាលរួចប្រើ ជីកំប៉ុស្តពី២ -៣ រទេះគោលើផ្ទៃដីសំណាប។ សាបគ្រាប់ស្រូវ១គីឡូក្រាម លើផ្ទៃដីថ្នាល១០ម៉ែត្រការ៉េ ដើម្បីឲ្យសំណាបដុះលូតលាស់ល្អ ។ សំណាបមានអាយុកាលពី១៥ទៅ២០ថ្ងៃ ត្រូវដកយកទៅស្ទូង ដោយដកភ្លាមស្ទូងភ្លាមនៅក្នុងថ្ងៃតែមួយ។

*សន្ទូង:* សំណាបមានអាយុកាលពី ១៥-២០ថ្ងៃ ត្រូវដកយកទៅស្ទូង ដោយដកភ្លាមស្ទូងភ្លាម នៅក្នុងថ្ងៃតែមួយ។ ស្រែសន្ទូងត្រូវភ្ជួរឲ្យបាន ២ ទៅ ៣ដង និងរាស់កៀរដីឲ្យបានរាបស្មើល្អ និងលើកភ្លឺស្រែឲ្យបានខ្ពស់និងជាប់ល្អ និងប្រើជីកំប៉ុស្ត ឬ ជីលាមកគោរលួយពុកល្អចំនួន៥តោន ឬ ២០រទេះគោ និងអាចប្រើជីដេ អា ប៉េ ចំនួន៥០គ.ក្រ ទៅ ១០០គ.ក្រ ទ្រាប់បាត តាមប្រភេទដី។ ស្ទូង១ដើម ទៅ ៣ដើមក្នុង១គុម្ពជាជួរ ឬមុំចង្រ្កាន ដោយស្ទូងចំនួន១៥ ទៅ ២០ គុម្ពក្នុង១ ម៉ែត្រការ៉េ។ បើដីមិនសូវមានជីជាតិអាចស្ទូងចំនួន១៥ ទៅ ២០ គុម្ពក្នុង១ម៉ែត្រការ៉េ (ចំពោះពូជស្រូវក្រអូប)។ ប្រើជីអ៊ុយរ៉េបំប៉នលើកទី១ ពី២៥ ទៅ ៥០គ.ក្រក្នុង១ហិកតាក្រោយស្ទូង៣០ថ្ងៃ និងលើកទី២ពី២៥ ទៅ ៥០គ.ក្រក្នុង១ហិកតា នៅពេលស្រូវមូរដើម ឬ ពេលស្រូវកកើតកួរ។ បើនៅលើដីល្បាយខ្សាច់វិញ ត្រូវប្រើជីប៉ូតាសស្យូមក្លរពី២៥ ទៅ ៥០គ.ក្រ ក្នុង១ហិកតា នៅពេលស្រូវមូរដើម ឬ ពេលស្រូវកកើតកួរ។ ក្រោយពេលស្ទូងរួចរយៈពេល៥ - ៧ថ្ងៃ ត្រូវស្ទូងជួសគុម្ពណាដែលបាត់ ចុះមើលស្រែជាប្រចាំ និងបោចស្មៅ គ្រប់គ្រង ថែទាំទឹកក្នុងស្រែ និងត្រួតពិនិត្យ សត្វល្អិត ជំងឺ និងសត្វមានប្រយោជន៍នៅក្នុងស្រែជាប្រចាំ។

## ខ. សម្រាប់ស្រូវពង្រោះ

*ការរៀបចំដីស្រែពង្រោះ និងព្រោះគ្រាប់ស្រូវ:* ត្រូវភ្ជួរដីឲ្យបានច្រើនដងពី២ ទៅ ៣ដងហើយរាស់កៀរដីឲ្យរាបស្មើល្អ និងប្រើជីកំប៉ុស្ត ឬជីលាមកគោដែលរលួយពុកល្អចំនួន៣-៥តោន ឬ ១៥ ទៅ ២០ រទេះគោតាមលទ្ធភាពរកបាន។ ព្រោះគ្រាប់ស្រូវពី៧០ ទៅ ១០០គីឡូក្រាមក្នុង១ហិកតា ដោយប្រើឧបករណ៍ព្រោះគ្រាប់ជាជួរ ឬ ព្រោះដោយដៃ ឲមានចំនួនដើមស្រូវពី៨០ ទៅ ១២០ដើមក្នុង១ម៉ែត្រការ៉េ ឬចំនួនដើមផ្តល់ផលកួរពី៣០០ ទៅ ៤០០ដើមក្នុង១ម៉ែត្រការ៉េ(IRRI,

2009)។

*ការប្រើប្រាស់ជី និងការថែទាំ:* បើដីស្រែមិនសូវមានជីជាតិអាចប្រើជីបន្ថែមដោយប្រើជីដេ អា ប៉េ ចំនួន ៥០ ទៅ ១០០គីឡូក្រាម ជីប៉ូតាស២៥គីឡូក្រាមក្នុង១ហិកតានៅពេលក្រោយព្រោះ១៥ ទៅ ២០ថ្ងៃ និងប្រើជីបំប៉នលើកទី១ ដោយប្រើជីអ៊ុយរ៉េចំនួន ២៥ គីឡូក្រាមក្នុង១ហិកតាក្រោយពេល ៣០ ថ្ងៃក្រោយពេលព្រោះ និងលើកទី២ ដោយប្រើជីអ៊ុយរ៉េ ចំនួនពី២៥គីឡូក្រាម និងជីប៉ូតាសចំនួន២៥គីឡូក្រាមក្នុង១ហិកតា នៅពេលស្រូវមូរដើម ឬ កកើតកួរ ។ ក្រោយពេលព្រោះរួចរយៈ ពេល ១៥ ទៅ ២០ ថ្ងៃ ត្រូវដាំជួសដើមណាដែលបាត់ ហើយចុះមើលស្រែជាប្រចាំ និងបោចស្មៅគ្រប់គ្រងថែទាំទឹកក្នុង ស្រែ និងត្រួតពិនិត្យ សត្វល្អិត ជំងឺ និងសត្វមានប្រយោជន៍នៅក្នុងស្រែជាប្រចាំ។

### ២.៣. ការប្រមូលផល និងទុកដាក់គ្រាប់ស្រូវ

*ការប្រមូលផលនិងទុកដាក់គ្រាប់ស្រូវ:* ត្រូវច្រូតកាត់នៅក្រោយពេលស្រូវចេញផ្កាស្រុះរយៈពេល៣០ទៅ៣៥ថ្ងៃ ឬ ពេលដែលគ្រាប់ស្រូវទុំប្រមាណ៨៥ភាគរយ ពេលគ្រាប់ស្រូវមានសភាពរឹងតែមិនស្រួយបាក់នៅពេលយកមកខាំ និងគ្រាប់ស្រូវមានអត្រាសំណើម២០- ២២ភាគរយ ។ ត្រូវបោកបែនភ្លាមក្រោយពីច្រូតកាត់ និងហាលគ្រាប់ស្រូវ ២-៣ថ្ងៃ ឲ្យសំណើមគ្រាប់មាន១៤ភាគរយ ឬគ្រាប់ស្រូវស្ងួតល្អមានសភាពរឹង តែមិនស្រួយបាក់នៅពេលខាំ ។ ដើម្បីឲ្យគ្រាប់ស្រូវស្ងួតល្អ ត្រូវទុកដាក់គ្រាប់ស្រូវក្នុងបាវក្រចៅ ឬជង្រុក ដែលជាទីកន្លែងស្ងួត និងមានខ្យល់ចេញចូលបានល្អ និងការពារបាននូវការបំផ្លាញពីសត្វល្អិត(ខ្មូត) និងសត្វកណ្ដុរ ។ ត្រូវកត់ត្រាថ្ងៃ ខែ ពេលប្រមូលផល នៅលើបាវស្រូវ ឬ ជង្រុកស្រូវ ។

## ៣.ពូជស្រូវធ្ងន់ប្រកាន់រដូវ

### ៣.១. លក្ខណៈពិសេសរបស់ពូជស្រូវ

*ក. ពូជស្រូវរាំងជ័យ*



ពូជរាំងជ័យ ជាពូជស្រូវធ្ងន់ ដែលបានបញ្ចេញនិង ផ្សព្វផ្សាយឲ្យកសិករប្រើប្រាស់ ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅឆ្នាំ ១៩៩៩ ហើយមកដល់បច្ចុប្បន្ននេះ ពូជស្រូវរាំងជ័យ កំពុងពេញនិយមប្រើប្រាស់ក្នុងផលិតកម្មស្រូវវស្សា ដោយកសិករនៅកម្ពុជា។ ពូជនេះមានទិន្នផលខ្ពស់ មានគុណភាពអង្ករល្អប្រសើរ មានភាពភ្លឺថ្លា និងបាយទន់ល្មម និងឆ្ងាញ់ពិសារ ។



ពូជរាំងជ័យជាប្រភេទ ពូជស្រូវប្រកាន់រដូវមធ្យមចាប់ចេញផ្កានៅពាក់កណ្ដាលខែវិច្ឆិកា និងច្រូតកាត់នៅពាក់កណ្ដាលខែធ្នូនិងដើមខែមករា អាស្រ័យតាមអាកាសធាតុ និងពេលវេលាដាំដុះ។ ពូជនេះមានកំពស់ដើមពី ១០៥ស.ម - ១៦៨ស.ម ចំនួនដើមបែកផ្តល់ផលពី ៥ ទៅ ១០ដើមក្នុង១គុម្ព ។ បើក្នុងលក្ខខណ្ឌដីមានជីជាតិល្អ និងអនុវត្តដាំដុះតាមប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវចំនួនដើមបែក ផ្តល់ផលអាចមានទៅដល់១៥ - ២០ដើមក្នុង១គុម្ព។ ប្រវែងកួរមានពី១៦ ទៅ ៣០ស.ម និងចំនួនគ្រាប់ក្នុង១កួរមានពី១៨៦ ទៅ ៣៣៨គ្រាប់ ។ ពូជរាំងជ័យ ជាប្រភេទពូជធន់ទ្រាំមធ្យម ទៅនឹងការលិចទឹកជំនន់ តែវាមិនសូវធន់នឹងមមាចត្នោតទេ ហើយមានទិន្នផលពី ៣.៥តោន ទៅ ៥.៥តោនក្នុង១ហិកតា។

*ខ. ពូជស្រូវខា៤*

ពូជខា៤ជាពូជស្រូវធ្ងន់ ដែលបានបញ្ចេញ និងផ្សព្វផ្សាយឲ្យកសិករប្រើប្រាស់ ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅឆ្នាំ១៩៩៥ ហើយមកដល់បច្ចុប្បន្ននេះ ពូជស្រូវខា៤បានកំពុងពេញនិយមប្រើប្រាស់ និងប្រជាកសិករធ្វើការ

ដាំដុះ នៅក្នុងផលិតកម្មរដូវស្រូវវស្សាទូទាំងប្រទេស ជាពិសេសនៅតំបន់ស្រែទឹកជម្រៅ ។ ពូជនេះមានទិន្នផលខ្ពស់ មានគុណភាពអង្ករល្អប្រសើរមានភាពភ្លឺថ្លា បាយទន់ និងឆ្ងាញ់ពិសារទៀតផង។



ពូជខា៤ ជាប្រភេទពូជស្រូវធ្ងន់ប្រកាន់រដូវ ចាប់ចេញផ្កានៅពាក់កណ្ដាលវិច្ឆិកា និងច្រូតកាត់ នៅពាក់កណ្ដាលខែធ្នូ អាស្រ័យតាមអាកាសធាតុ និងពេលវេលាដាំដុះ។ ពូជនេះ មានកម្ពស់ដើមពី ១៣២ ស.ម - ១៧៣ ស.ម ចំនួនដើមបែកផ្ដល់ផលពី ៦ - ១០ដើមក្នុង១គុម្ព។ បើក្នុងលក្ខខណ្ឌដីមានជីជាតិល្អ និងអនុវត្តដាំដុះតាមប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ ចំនួនដើមបែក ផ្ដល់ផលអាចមានទៅដល់២០ ទៅ ២៥ដើមក្នុង១គុម្ព ។ ប្រវែងកួរមានពី២២ ទៅ ២៥ ស.ម និងចំនួនគ្រាប់ក្នុង១កួរមានពី១៦០ ទៅ ១៩០គ្រាប់។ ពូជខា៤ ជាប្រភេទពូជធន់ទៅនឹងភាពរាំងស្ងួត ប៉ុន្តែវាមិនសូវធន់នឹងមមាចត្នោតទេ ហើយមានទិន្នផលពី ២.៥តោន ទៅ ៥.០តោនក្នុង១ហិកតា។

*គ. ពូជស្រូវខា៦*

ពូជផ្កាខា៦ជាពូជស្រូវធ្ងន់ ដែលបានបញ្ចេញ និងផ្សព្វផ្សាយឲ្យកសិករប្រើប្រាស់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅឆ្នាំ២០០៥ ហើយមកដល់បច្ចុប្បន្ននេះ ពូជស្រូវខា៦ កំពុងពេញនិយមប្រើប្រាស់ ក្នុងផលិតកម្មស្រូវវស្សាដោយកសិករនៅទូទាំងប្រទេស។ ពូជនេះមានទិន្នផលខ្ពស់ មានគុណភាពអង្ករល្អមានភាពភ្លឺថ្លា និងបាយទន់ឆ្ងាញ់ពិសារ។

ពូជខា៦ ជាប្រភេទពូជស្រូវធ្ងន់ប្រកាន់រដូវ ចាប់ចេញផ្កាពីថ្ងៃ៩ - ១៦ ខែវិច្ឆិកា និងច្រូតកាត់ នៅពាក់កណ្ដាលទៅចុងខែធ្នូ អាស្រ័យតាមអាកាសធាតុនិងពេលវេលាដាំដុះ។ ពូជនេះមានកំពស់ដើមពី ១២៩ស.ម - ១៧៧ស.ម ចំនួនដើមបែកផ្ដល់ផលពី ៧ ទៅ៩ ដើមក្នុង១គុម្ពបើក្នុងលក្ខខណ្ឌដីមានជីជាតិល្អ និងអនុវត្តដាំដុះតាមប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ ចំនួនដើមបែកផ្ដល់ផលអាចមានទៅដល់ ១៥ ទៅ២០ដើមក្នុង១គុម្ព។ ប្រវែងកួរមានពី២១ ទៅ ២៥ ស.ម និងចំនួនគ្រាប់ក្នុង១កួរមានពី១៥៥ ទៅ ១៨៨ គ្រាប់។ ពូជខា៦ មានទិន្នផលពី ៣.៥តោន ទៅ ៥.៨តោនក្នុង១ហិកតា។

### ៣.២ បច្ចេកទេសដាំដុះ

### ក. សម្រាប់ស្រូវសន្ទូង

*សំណាប:* ដើម្បីឲ្យសំណាប និងដើមស្រូវមានសុខភាពល្អ ត្រូវប្រើពូជស្រូវសុទ្ធ និងមានគុណភាពល្អ ដោយប្រើពូជពី ២០- ៤០គីឡូក្រាមសម្រាប់ស្ទូង១ហិកតា។ បើស្ទូងតាមប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវវិញ ប្រើពូជតែពី ១៥ - ២០ គីឡូក្រាមសម្រាប់ស្ទូង១ហិកតា ។ ថ្នាលសំណាបត្រូវនៅជិតប្រភពទឹក ត្រូវរៀបចំដីថ្នាលសំណាបឲ្យបានស្មើល្អដោយភ្ជួរ និងរាស់ឲ្យបានច្រើនដង និងកៀរដីថ្នាលរួចប្រើ ជីកំប៉ុស្តពី២ ទៅ ៣រទេះគោលើផ្ទៃដីសំណាប។ សាបគ្រាប់ស្រូវគីឡូក្រាមលើផ្ទៃដីថ្នាល១០ម៉ែត្រការ៉េ ដើម្បីឲ្យសំណាបដុះលូតលាស់ល្អ ។ សំណាបមានអាយុកាលពី១៥- ២០ថ្ងៃ ត្រូវដកយកទៅស្ទូង ដោយដកភ្លាមស្ទូងភ្លាមនៅក្នុងថ្ងៃតែមួយ។

*សន្ទូង:* សំណាបមានអាយុកាលពី១៥ - ២០ថ្ងៃ ត្រូវដកយកទៅសន្ទូងដោយដកភ្លាមស្ទូងភ្លាមនៅក្នុងថ្ងៃតែមួយ។ ស្រែសន្ទូងត្រូវភ្ជួរឲ្យបាន២- ៣ដង និងរាស់កៀរដីឲ្យបានរាបស្មើល្អ និងលើកភ្លឺស្រែឲ្យបានខ្ពស់និងជាប់ល្អ និងប្រើជីកំប៉ុស្ត ឬជីលាមកគោរលួយពុកល្អចំនួន៥តោន ឬ ២០រទេះគោ និងអាចប្រើជីដេ អា ប៉េ ចំនួន៥០គ.ក្រ ទៅ ១០០ គ.ក្រ ទ្រាប់បាតទៅតាមប្រភេទដី។ ស្ទូង១ដើម ទៅ ៣ដើមក្នុង១គុម្ពជាជួរ ឬ មុំចង្រ្កាន ដោយស្ទូងចំនួន១០ ទៅ ១៥ គុម្ពក្នុង១ម៉ែត្រការ៉េ ។ បើដីមិនសូវមានជីជាតិអាចស្ទូងចំនួន១៥ ទៅ ២០ គុម្ពក្នុង១ម៉ែត្រការ៉េ។ ជីបំប៉នអាចប្រើពី២-៣លើកគឺ:បំប៉នលើកទី១ប្រើជីអ៊ុយរ៉េ ២៥ គ.ក្រក្នុង១ហិកតា ក្រោយស្ទូង៣០ថ្ងៃ បាចជីបំប៉នលើកទី២ ប្រើជីអ៊ុយរ៉េ២៥ គ.ក្រ ក្នុង១ហិកតា នៅពេលក្រោយបាចជីបំប៉នលើកទី១ ៣០ថ្ងៃ និងលើកទី៣ ប្រើជីអ៊ុយរ៉េ ២៥ គ.ក្រក្នុង១ហិកតា នៅពេលស្រូវមូរដើម ឬពេលស្រូវកកើតកួរ។ បើនៅលើដីល្បាយខ្សាច់វិញ ត្រូវប្រើជីប៉ូតាសស្យូមក្លរួពី២៥ ទៅ ៥០គ.ក្រក្នុង១ហិកតានៅពេលស្រូវមូរដើម ឬ

ពេលស្រូវកកើតកូរ។ ក្រោយពេលស្ទូងរួចរយៈពេល៥ ទៅ ៧ថ្ងៃ ត្រូវស្ទូងជួសគុម្ពណាដែលបាត់ ចុះមើលស្រែជាប្រចាំ និងបោចស្មៅ គ្រប់គ្រងថែទាំទឹកក្នុងស្រែ និងត្រួតពិនិត្យ សត្វល្អិត ជំងឺ និងសត្វមានប្រយោជន៍នៅក្នុងស្រែជាប្រចាំ។

### ១. សម្រាប់ស្រូវពង្រោះ

*ការរៀបចំដីស្រែពង្រោះ និងព្រោះគ្រាប់ស្រូវ:* ត្រូវភ្ជួរដីឲ្យបានច្រើនដងពី២ -៣ ដង ហើយរាស់កៀរដីឲ្យរាបស្មើល្អ និងប្រើដីកំប៉ុស្ត ឬដីលាមកគោដែលរលួយពុកល្អចំនួន៣-៥តោន ឬ ១៥ - ២០រទេះគោតាមលទ្ធភាពរកបាន ។ ព្រោះគ្រាប់ស្រូវពី៧០ ទៅ ១០០គីឡូក្រាមក្នុង១ហិកតា ដោយប្រើឧបករណ៍ព្រោះគ្រាប់ជាជួរ ឬ ព្រោះដោយដៃ ឲមានចំនួនដើមស្រូវពី១០០ ទៅ ១៥០ ដើមក្នុង១ម៉ែត្រការ៉េ (IRRI, 2009)។

*ការប្រើប្រាស់ជី និងការថែទាំ:* បើដីស្រែមិនសូវមានជីជាតិអាចប្រើជី បន្ថែមដោយប្រើជីដេ អា ប៉េ ចំនួន ៥០-១០០ គីឡូក្រាមជីប៉ូតាស២៥គីឡូក្រាមក្នុង១ហិកតានៅពេលក្រោយព្រោះ១៥ - ២០ថ្ងៃ និងប្រើជីបំប៉នលើកទី១ ដោយប្រើជីអ៊ុយរ៉េចំនួន ២៥គីឡូក្រាមក្នុង១ហិកតា ៣០ ថ្ងៃក្រោយពេលព្រោះ និងលើកទី២ ដោយប្រើជីអ៊ុយរ៉េ ចំនួន ពី២៥ គ.ក្រ និងជីប៉ូតាសចំនួន២៥គីឡូក្រាមក្នុង១ហិកតានៅពេលស្រូវមូរដើម ឬ កកើតកូរ ។ ក្រោយពេលព្រោះរួចរយៈពេល ១៥-២០ថ្ងៃ ត្រូវដាំជួសដើមណាដែលបាត់ ហើយចុះមើលស្រែជាប្រចាំ និងបោចស្មៅ គ្រប់គ្រងថែទាំទឹកក្នុងស្រែ និងត្រួតពិនិត្យ សត្វល្អិត ជំងឺ និងសត្វមានប្រយោជន៍នៅក្នុងស្រែជាប្រចាំ។

### ៣.៣. ការប្រមូលផល និងទុកដាក់គ្រាប់ស្រូវ

*ការប្រមូលផលនិងទុកដាក់គ្រាប់ស្រូវ:* ត្រូវច្រូតកាត់នៅក្រោយពេលស្រូវចេញផ្កាស្រុះរយៈពេល៣០ ទៅ ៣៥ថ្ងៃ ឬ ពេលដែលគ្រាប់ស្រូវទុំប្រមាណ៨៥ភាគរយ ពេលគ្រាប់ស្រូវមានសភាពរឹង តែមិនស្រួយបាក់នៅពេលយកមកខាំ និងគ្រាប់ស្រូវមានអត្រាសំណើម២០- ២២ភាគរយ ។ ត្រូវបោកបែនភ្លាមក្រោយពីច្រូតកាត់ និងហាលគ្រាប់ស្រូវ២-៣ ថ្ងៃ ឲ្យសំណើមគ្រាប់មាន១៤ភាគរយ ឬគ្រាប់ស្រូវស្ងួតល្អមានសភាពរឹង តែមិនស្រួយបាក់នៅពេលខាំ។ ដើម្បីឲ្យគ្រាប់ស្រូវស្ងួតល្អ ត្រូវទុកដាក់គ្រាប់ស្រូវក្នុងបាវក្រចៅ ឬជង្រុក ដែលជាទីកន្លែងស្ងួត និងមានខ្យល់ចេញចូលបានល្អ និងការពារបាននូវការបំផ្លាញពីសត្វល្អិត(ខ្មូត) និងសត្វកណ្តុរ ។ ត្រូវកត់ត្រាថ្ងៃ ខែ ពេលប្រមូលផល នៅលើបាវស្រូវ ឬ ជង្រុកស្រូវ ។

## ឯកសារយោង


1. វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា ព្រឹត្តិប័ត្រព័ត៌មានកសិករ ឆ្នាំទី១លេខ០១ ខែ មិថុនា ឆ្នាំ ២០០២, ឆ្នាំទី១លេខ៧ ខែធ្នូ ឆ្នាំ២០០២ ឆ្នាំទី៣លេខ២៥ ខែមិថុនា ឆ្នាំ២០០៤, ឆ្នាំទី៣ លេខ៣១ ខែធ្នូ ឆ្នាំ ២០០៤, ឆ្នាំទី៤ លេខ៤៣ ខែធ្នូ ឆ្នាំ ២០០៥, ឆ្នាំទី៥លេខ៤៩ ខែ មិថុនា ឆ្នាំ២០០៦, ឆ្នាំទី៦លេខ៥៨ ខែ មីនាឆ្នាំ ២០០៧, ឆ្នាំទី៦ លេខ៥៩ ខែ មេសា ឆ្នាំ ២០០៧, ឆ្នាំទី៩លេខ៩២ ខែ មករា ឆ្នាំ ២០១០ និង ឆ្នាំទី៩លេខ៩៨ ខែ កក្កដា ឆ្នាំ ២០១០។
2. ម៉ាក់ សឿន យុទ្ធសាស្ត្រគ្រប់គ្រងជីជាតិដី នៅក្នុងតំបន់ក្សេត្របរិស្ថានដំណាំស្រូវស្រែទំនាបពឹងដោយទឹកភ្លៀងនៅកម្ពុជា ខែ មេសា ឆ្នាំ២០១០, ១០៦ទំព័រ។
3. រាជរដ្ឋាភិបាលកម្ពុជា គោលនយោបាយជំរុញផលិតកម្មស្រូវ និងជំរុញការនាំចេញអង្ករ ថ្ងៃទី១៧ ខែ សីហាឆ្នាំ២០១០។
4. Buresh J R., (2009).Site-Specific Nutrient Management (SSNM): An Approach for Optimizing Nutrient Use in Rice Production,. IRRI, Philippines. www.irri.org/irrc/ssnm;
5. International Rice Research Institute (IRRI). (2009) Rice Knowledge Bank. Good Agricultural Practices (GAP) for Irrigated and Rainfed Rice, Philippines. www.knowledgebank.irri.org;
6. Men Sarom., Chauddhary R.C., Javier E., Ouk M.,Sakhan S., Hun Y., Pith K H., Sidhu G S., Sin S., Say P., Ung S.P., Preap. V.,(2001). Discription of Rice Varieties Released by Rice Recommendation Committee of Cambodia (1990-2000), CARDI, Phnom Penh, Cambodia. 75p